# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (អនុវត្តន៍សំណង់អគារ)

សំណួរទី 1
តើគ្រឿងចក្រសំណង់ក្នុងរូបថតគឺជាអ្វី?

1. រថយន្តបែន
2. អេស្កាវ៉ាទ័រអ៊ីដ្រូលីក
3. អេស្កាវ៉ាទ័រ (Power shovel)
4. ប៊ុលដូហ្ស័រ



ចម្លើយៈ 4

សំណួរទី 2
តើឧបករណ៍នៅក្នុងរូបថតគឺជាអ្វី?

1. កន្ត្រៃកាត់លួសក្រាស់
2. សោមាត់អក្សរអ៊ីយ
3. ដែកចងលួស (Hakka)
4. ដែកចងលួស (Shino)



ចម្លើយ៖ 1

# វិញ្ញាសាគំរូ ការប្រឡងវាយតម្លៃពលករជំនាញកម្រិត 1 ផ្នែកសំណង់ (អនុវត្តន៍សំណង់អគារ)

សំណួរទី 3

តើក្នុងរូបថតគឺជាឧបករណ៍សម្រាប់ធ្វើអ្វី?

1. តភ្ជាប់សរសៃដែក
2. រំលាយសរសៃដែក
3. ពត់សរសៃដែក



ចម្លើយៈ 3

សំណួរទី 4

តើក្នុងរូបថតគឺជាសភាពកំពុងធ្វើអ្វី?



1. ជីករណ្ដៅជ្រៅនៅដី។
2. បញ្ជូនខ្យល់ក្រោមដី។
3. កម្ចាត់ពពុះក្នុងបេតុង។
4. បង្ហាប់ដី។

ចម្លើយ ៖ 4

សំណួរទី 5
តើក្នុងរូបថតគឺជាឧបករណ៍សម្រាប់ធ្វើអ្វី?



1. គូសគំនូសសម្គាល់ជាខ្សែត្រង់វែងលើផ្ទៃសម្ភារជាដើម។
2. ធ្វើឱ្យមានស្នាមទ្រុឌតូចលើផ្ទៃលោហៈ។
3. វាស់ជម្រៅសមុទ្រ ទន្លេជាដើម។
4. ពិនិត្យភាពបញ្ឈរត្រង់នៃសសរជាដើម។

ចម្លើយ ៖ 4

សំណួរទី 6
តើការគូសសញ្ញាសម្គាល់កម្ពស់និងទីតាំងសម្ភារនិងរចនាសម្ព័ន្ធដែលត្រូវធ្វើការសាងសង់នៅការដ្ឋានសាងសង់ ហៅថាអ្វី?

1. ការជំ
2. ការធ្វើឲ្យចេញពណ៌ស្អាត
3. ការធ្វើឲ្យចេញជ្រុង
4. ការគូសគំនូសសម្គាល់

ចម្លើយ ៖ 4

សំណួរទី 7
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។
បេតុងគឺ(          ) ដូច្នេះវាអាចការពារសរសៃដែកពីច្រែះបាន។

1. មានលក្ខណៈបាស
2. មានលក្ខណៈអាសុ៊ីត
3. រឹង
4. រាវ

ចម្លើយៈ 1

សំណួរទី 8
វិធីសាស្ត្រតាមបែបបុរាណដែលគេផ្គុំបញ្ចូលគ្នានូវសម្ភារផ្ដេកដូចជាបាតទម្រ(foundation) ផ្ទឹម ឃ្នាបជាដើមជាមួយសសរដែលជាសម្ភារបញ្ឈរ ក្នុងសំណង់ឈើ តើហៅថាអ្វី?

1. វិធីសាស្ត្រសាងសង់ដំឡើងគ្រោងឈើ
2. វិធីសាស្ត្រសាងសង់ 2×4
3. វិធីសាស្ត្រសាង់សង់ដំឡើងគ្រោងជញ្ជាំង
4. វិធីសាស្ត្រក្រាលបាយអ

ចម្លើយៈ 1

សំណួរទី 9
ក្នុងការងារជញ្ជាំងខាងក្រៅ តើវិធីសាស្ត្រដែលក្រាលសម្ភារថ្មដូចជាថ្មម៉ាប ថ្មក្រានីតជាដើមដោយបាយអជាដើម ហៅថាអ្វី?

1. វិធីសាស្ត្របៀកភ្ជាប់
2. វិធីសាស្ត្របិទការ
3. វិធីសាស្ត្របែបស្ងួត
4. វិធីសាស្ត្របែបសើម

ចម្លើយ ៖ 4

សំណួរទី 10
ទាក់ទងនឹងចំនួនករណីកើតឡើងនៃគ្រោះថ្នាក់ស្លាប់របស់និយោជិតបរទេសក្នុងឆ្នាំ 2021 ប្រភេទគ្រោះថ្នាក់ដែលមានច្រើនបំផុតគឺមួយណាក្នុងចំណោមខាងក្រោម?

1. ធ្លាក់/រអិលធ្លាក់
2. ខ្ទាត/ធ្លាក់ត្រូវ
3. គាបជាប់/រមួលចូល

ចម្លើយៈ 1

សំណួរទី 11
ក្នុងចំណោមប្រភេទនៃគ្រោះថ្នាក់ស្លាប់ ឃ្លាដែលនិយាយអំពីការធ្លាក់/រអិលធ្លាក់ តើគឺមួយណាក្នុងចំណោមខាងក្រោម?

1. កើតឡើងបណ្តាលមកពីការដួលដោយជំពប់នឹងវត្ថុជាដើម ឬដួលដោយបាត់លំនឹង

2. កើតឡើងបណ្តាលមកពីការធ្លាក់តាមលំហរវាងជាន់នីមួយៗពេលកំពុងសាងសង់ ឬប្រហោងជាដើមពេលកំពុងជីក
3. កើតឡើងបណ្តាលមកពីការគាបជាប់ឬរមួលចូលក្នុងម៉ាស៊ីន

ចម្លើយ៖ 2

សំណួរទី 12
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង(          ) ក្នុងប្រយោគខាងក្រោម។

ក្នុងការត្រួតពិនិត្យមុនចាប់ផ្តើមការងារ ត្រូវត្រួតពិនិត្យសុវត្ថិភាពដូចជាត្រួតពិនិត្យ (          ) បញ្ជាក់ការងារជាដើម មុនចាប់ផ្តើមការងារ។

1. ម៉ាស៊ីននិងឧបករណ៍ជាដើមដែលប្រើប្រាស់
2. សម្លៀកបំពាក់
3. ស្ថានភាពសុខភាព

ចម្លើយៈ 1

សំណួរទី 13
ចូរជ្រើសរើសពាក្យដែលត្រូវដាក់ក្នុង( ) ក្នុងប្រយោគខាងក្រោម។

( ) មុនចាប់ផ្តើមការងារ គឺជាឱកាសអាចឲ្យអ្នកជំនាញជើងចាស់ចែករំលែកបទពិសោធន៍ពីការព្យាករគ្រោះថ្នាក់ដែលអាចកើតមាន។

1. សកម្មភាព KY
2. សកម្មភាព DP

ចម្លើយ៖ 1